FARMER NOTES

# ព្រឹត្តិប័ត្រព័ត៌មានកសិករ



ការបោះពុម្ពផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute

## ការរៀបចំសហគមន៍ ដើម្បីគ្រប់គ្រងកណ្តុរស្រែ

កណ្តុរស្រែ ជាសត្វចង្រៃមួយក្នុងចំណោមសត្វចង្រៃដែលធ្វើឱ្យបាត់បង់ទិន្នផលស្រូវយ៉ាងធ្ងន់ធ្ងរ។ ម៉្យាងទៀត សត្វកណ្តុរមានការលំបាកក្នុងការកំចាត់បើសិនជាកសិករមិនបានសហការគ្នាល្អ ក្នុងការកម្ចាត់កណ្តុរនេះ។ គម្រោងនេះ បានបង្កើតការគ្រប់គ្រងសត្វកណ្តុរជាលក្ខណៈសហការគ្នា ឬជាសហគមន៍ ដោយប្រើប្រាស់វិធីសាស្ត្រ ធី-ប៊ី-អេស ។ ធី-ប៊ី-អេស មានន័យថាជាប្រពន្ធ័គ្រប់គ្រងសត្វកណ្តុរស្រែមួយរួមមានរបាំងប្លាស្ទិច អង្គប់ និងដំណាំផ្ទាក់។ ប្រពន្ធ័គ្រប់គ្រងនេះទាមទារចាំបាច់នូវការចូលរួមរបស់កសិករទាំងអស់ដែលមានស្រែនៅក្បែរៗគ្នា។



### សារៈប្រយោជន៍នៃការរៀបចំសហគមន៍កសិករ

- ធ្វើឱ្យមានប្រសិទ្ធិភាពខ្ពស់ និងនិរន្តរភាពក្នុងការគ្រប់គ្រង
- ជំរុញការចូលរួមរបស់កសិករក្នុងការអនុវត្តន៍ការងារ
- បង្កើនសាមគ្គីភាពនៅក្នុងមូលដ្ឋាន
- បង្កភាពងាយស្រួលដល់ការអនុវត្តន៍ការងារ
- បង្កើនភាពទទួលខុសត្រូវរបស់កសិករ
- ជំរុញការចូលរួមវិភាគទានរបស់កសិករនៅក្នុងការអនុវត្តន៍ការងារ ដើម្បីកាត់បន្ថយការចំណាយថវិកា និងកម្លាំងពលកម្មគ្រួសារ

អាស្រ័យហេតុនេះ ការចងក្រងជាសហគមន៍ជាយុទ្ធវិធីដ៏សំខាន់ ក្នុងការគ្រប់គ្រងកណ្តុរស្រែដោយ ធី-ប៊ី-អេស។



### ជំហាននៃការរៀបចំក្រុមកសិករ

- ផ្សព្វផ្សាយពីវិធីសាស្ត្រ ធី-ប៊ី-អេស ដល់កសិករនៅទីកន្លែងដែលនឹងអនុវត្ត
- កំណត់ទីតាំងស្រែទទួលរងការបំផ្លាញពីសត្វកណ្តុរលើស្រែកសិករ
- ជ្រើសរើសសមាជិកក្រុមកសិករចូលរួមក្នុងការអនុវត្តន៍

- ការឯកភាពនៅក្នុងក្រុមកសិករ និង
- ធ្វើទិវាស្រែបង្ហាញដល់កសិករក្នុងក្រុម។

## ការផ្សព្វផ្សាយវិធីសាស្រ្ត ធី-ប៊ី-អេស

អាជ្ញាធរមូលដ្ឋាន និងអ្នកបច្ចេកទេស ព្រមទាំងអ្នកផ្សព្វផ្សាយសហការជាមួយកសិករសកម្ម រៀបចំធ្វើការប្រជុំក្រុមកសិករតាមភូមិ ឬតំបន់ដែលមានការបំផ្លាញពីសត្វកណ្តុរ។ ការប្រជុំនេះត្រូវផ្តោតទៅលើចំណុចសំខាន់មួយចំនួនដូចខាងក្រោម ៖

- ផ្សព្វផ្សាយពីបច្ចេកទេស ធី-ប៊ី-អេស ដល់កសិករ
- បង្ហាញពីសារៈប្រយោជន៍នៃការប្រើប្រាស់ ធី-ប៊ី-អេស ក្នុងការគ្រប់គ្រងសត្វកណ្តុរ
- ពន្យល់ពីសារៈប្រយោជន៍នៃការធ្វើការរួមគ្នាក្នុងសហគមន៍
- រៀបចំផែនការដើម្បីកំណត់តំបន់ទទួលរងការបំផ្លាញពីសត្វកណ្តុរ។

## ការកំណត់តំបន់ទទួលរងការបំផ្លាញពីសត្វកណ្តុរ

អ្នកសម្របសម្រួល និងក្រុមកសិករ (ដែលយល់ដឹងពីទីតាំងភូមិសាស្រ្តច្បាស់លាស់) ត្រូវសិក្សាទីតាំងដែលមានការបំផ្លាញពីសំណាក់សត្វកណ្តុរ ។

- កំណត់ចំនួនតំបន់ដែលគ្រោងនឹងអនុវត្តធី-ប៊ី-អេស
- សិក្សាពីសក្តានុពលនៃតំបន់ ដើម្បីរៀបចំជ្រើសរើសកូនស្រែធី-ប៊ី-អេស
- កំណត់កូនស្រែ ធី-ប៊ី-អេស នៅក្នុងតំបន់ដែលបានជ្រើសរើស។

## ការជ្រើសរើសសមាជិកក្រុមកសិករចូលរួម

អាជ្ញាធរមូលដ្ឋានត្រូវធ្វើការជ្រើសរើសកសិករដើម្បីបង្កើតនូវក្រុមការងារសម្រាប់អនុវត្ត ធី-ប៊ី-អេស។ ការជ្រើសរើសកសិករឱ្យចូលរួមត្រូវផ្អែកលើលក្ខណៈមួយចំនួនដូចខាងក្រោម ៖

- កសិករដែលមានកូនស្រែនៅជុំវិញកូនស្រែ ធី-ប៊ី-អេស (២០០ ម៉ែត្រជុំ វិញ)
- ការចូលរួមរបស់កសិករត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត
- កសិករដែលទទួលរងនូវការបំផ្លាញពីសត្វកណ្តុរ
- កសិករដែលមានចំណាប់អារម្មណ៍ និងយកចិត្តទុកដាក់លើការងារនេះ
- កូនស្រែ ធី-ប៊ី-អេស មួយ ត្រូវទទួលខុសត្រូវដោយក្រុមកសិករមួយក្រុម
-

### ការរៀបចំស្រែបង្ហាញ

ដើម្បីឱ្យកសិករកាន់តែយល់ច្បាស់ពីបច្ចេកទេសនៃការរៀបចំធី-ប៊ី-អេស អ្នកសម្របសម្រួល និងអាជ្ញាធរមូលដ្ឋាន ត្រូវរៀបចំធ្វើទិវាស្រែបង្ហាញ ដល់ក្រុមកសិករ ។ ទិវាស្រែបង្ហាញនេះរួមមាន:

- កូនស្រែ ធី-ប៊ី-អេស គំរូត្រូវរៀបចំទុកជាមុន
- បង្ហាញពីបច្ចេកទេសនៃការរៀបចំសម្ភារៈ ការតម្លើងឧបករណ៍ក្នុងកូនស្រែ និងវិធីតាមដានកូនស្រែធី-ប៊ី-អេស
- បង្ហាញពីការលំបាក និង ភាពងាយស្រួលក្នុងការអនុវត្តនូវបច្ចេកទេស ធី-ប៊ី-អេស ។



## ការឯកភាពក្នុងក្រុមកសិករ



ការឯកភាពក្នុងក្រុម ជាការធ្វើការព្រមព្រៀងរវាងកសិករនៅក្នុងក្រុម ធី-ប៊ី-អេស។ ការព្រមព្រៀងនេះធ្វើឡើងដោយឡែកៗពីគ្នានៅក្នុងក្រុម ធី-ប៊ី-អេស នីមួយៗ ដោយមានការចូលរួមពីអ្នកសម្របសម្រួល និងអាជ្ញាធរមូលដ្ឋាន។ ចំណុចសំខាន់ៗដែលលើកឡើងនៅក្នុងការងារនេះ រួមមាន:

- ជ្រើសរើសប្រធានក្រុមការងារនៅក្នុងក្រុម ធី-ប៊ី-អេស ដោយសមាជិកនៅក្នុងក្រុម ធី-ប៊ី-អេស របស់ខ្លួន
- កំណត់កម្រិតការចូលរួមវិភាគទានពីសមាជិកក្នុងក្រុម ធី-ប៊ី-អេស
- កំណត់ទីតាំងកូនស្រែ ធី-ប៊ី-អេស និងម្ចាស់កូនស្រែ
- រៀបចំផែនការសកម្មភាពការងារក្នុងក្រុមដើម្បីដំណើរការ ធី-ប៊ី-អេស។